**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០០៨/០៣/២០០៨ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០០៨

**ជម្រាបមក**

**ក្រុមអ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី**

**កម្មវត្ថុ** : រឿងទាក់ទងនឹងបណ្តឹងរបស់ក្រុមអ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី ប្តឹងគណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត ពីការរំលោភលើសិទ្ធិបោះឆ្នោតរបស់ប្រជាពលរដ្ឋ ដែលមានចែងក្នុងមាត្រា ៣៤ ថ្មី នៃរដ្ឋធម្មនុញ្ញ

**យោង** : បណ្តឹងគ្មានលេខ ចុះថ្ងៃទី២៨ ខែ កក្កដា ឆ្នាំ២០០៨ របស់ក្រុមអ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោកជំទាវជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០០៨ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យលើបណ្តឹងនេះរួចហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា ពុំអាចលើកយកបណ្តឹងនេះមកពិភាក្សា និង សម្រេចបានឡើយ ពីព្រោះបណ្តឹងរបស់ឯកឧត្តម លោកជំទាវ មិនចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានចែងក្នុងមាត្រា ២៥ ថ្មី មាត្រា ២៦ និង មាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និង មាត្រា ៧៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នោះទេ ។

សូមឯកឧត្តម លោកជំទាវ ទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**